ថែរក្សាទីក្រុងឡូវែល   រក្សាសុវត្ថិភាពរបស់អ្នក   រក្សាអ្នកឲ្យមានសុខភាពល្អ

សូមកុំអោយការភ័យខ្លាចនៃរោគកូវិដ -១៩ រារាំងអ្នកពីការទទួលបានការថែរក្សាសុខភាពជាប្រចាំ។

- យើងរង់ចាំទទួលអ្នក ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៍ សូមទូរស័ព្ទទៅ ៩៧៨.៩៣៧.៩៧០០
- ពេលនេះយើងមិនទទួលយកអ្នកដែលមិនមានការណាត់ជួបឡើយ។ សូមទូរស័ព្ទទៅមុនសិន មុននឹងអ្នកធ្វើដំណើរទៅមណ្ឌលសុខភាព។
- ការណាត់ជួបមួយចំនួននឹងត្រូវបានធ្វើតាមរយៈទូរស័ព្ទ ហើយខ្លះទៀតនឹងជួបនៅមណ្ឌលសុខភាព។ យើងនឹងពិភាក្សារឿងនេះនៅពេលអ្នកដាក់ការណាត់ជួប។
- មណ្ឌលសុខភាពសហគមន៍ឡូវែលមានសុវត្ថិភាពល្អ។ យើងមានការសម្អាតជាញឹកញាប់នាពេលថ្ងៃនិងពេលយប់, ថែមទាំងគោរពតាមបទបញ្ជាឲ្យនៅឆ្ងាយពីគ្នាផងដែរ។
- សុខភាព និងសុវត្ថិភាពរបស់អ្នកគឺរឿងចំបងរបស់យើងខ្ញុំ។ ដើម្បីជួយកាត់បន្ថយការរីករាលដាលនៃការឆ្លង:
  - សូមពាក់ម៉ាស! ប្រសិនបើអ្នកមិនមាន យើងខ្ញុំនឹងត្រូវផ្តល់ជូន។
  - នៅពេលដែលអ្នកចូលដល់ក្នុងអាគារ បុគ្គលិកយើងនឹងស្វាគមន៍អ្នក ពិនិត្យសុខភាព និងវាស់សីតុណ្ហភាពរបស់អ្នក។ អ្នកនឹងត្រូវបានស្នើសុំឱ្យប្រើសាប៊ូអនាម័យដែលយើងនឹងផ្តល់ជូន។
  - បន្ទាប់មកអ្នកនឹងជិះជណ្តើរយន្តទៅជួបជាមួយគ្រូពេទ្យរបស់អ្នក រួចហើយនឹងទទួលបាននូវព័ត៌មានផ្សេងៗទៀត។

យើងនៅទីនេះសម្រាប់បម្រើលោកអ្នក។ ប្រសិនបើអ្នកមានកង្វល់ឬសំណួរសូមទូរស័ព្ទមកលេខ ៩៧៨.៩៣៧.៩៧០០។